# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ១៧៥៥ កសក

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ មករា ឆ្នាំ២០១៦

**សូមគោរពជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ៖** របាយការណ៍ស្តីពីស្ថានភាពនៃការបំពេញបែបបទនាំចេញអង្ករក្នុងឆ្នាំ២០១៥។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមអនុញ្ញាតជម្រាបជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពដ៏ខ្ពង់ខ្ពស់មេត្តាជ្រាបថា នៅក្នុងឆ្នាំ២០១៥ នេះ ស្ថានភាពនៃការនាំចេញអង្ករទៅក្រៅប្រទេសដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលបានដោយផ្អែកលើប្រព័ន្ធទិន្នន័យត្រួតពិនិត្យភូតគាមអនាម័យជាតិ National Phytosanitary database (NPD/GDA from 07:00/01.01.2015 to 17:00/31.12.2015) ដែលជាតួលេខនៃការនាំចេញតាមរយៈការរៀបចំវេចខ្ចប់គ្រប់ចំនួនរួចជាស្រេច និងបានឆ្លងកាត់ការត្រួតពិនិត្យភូតគាមអនាម័យដើម្បីនាំចេញមានដូចខាងក្រោម ៖

១ - **ស្ថានភាពនៃការនាំចេញអង្ករ៖**

- បរិមាណអង្ករនាំចេញមានចំនួន៥៣៨.៣៩៦តោន មានការកើនឡើងចំនួន១៥១.៣៣៥តោន (+៣៩.១%) លើសឆ្នាំ២០១៤ ដែលនាំចេញបានតែ៣៨៧.០៦១តោន។ ដោយឡែក បរិមាណអង្ករនាំចេញក្នុងខែធ្នូ ឆ្នាំ២០១៥នេះ មានចំនួន៨១.៤៧៩តោន ដែលមានកំណើនចំនួន៣០.៣៤៣តោន (+៥៩,៣%) លើបរិមាណនាំចេញក្នុងខែធ្នូ ឆ្នាំ២០១៤ ដែលនាំចេញបានតែ៥១.១៣៦តោន (សូមបង្ហាញជូនក្នុងតារាងទី១នៃឧបសម្ព័ន្ធ)

- អង្ករក្រអូបគ្រប់ប្រភេទមានបរិមាណនាំមុខគេដែលមានកំណើនកើនឡើងរហូតដល់២៧៤.៦៧១តោន ស្មើនឹង៥១% អង្ករ ស គ្រប់ប្រភេទមានចំនួន២២១.៨៦២តោន ស្មើនឹង៤១,២% និង អង្ករចំហុយមាន៤១.៨៦៣តោន ស្មើនឹង៧,៨%។ ក្នុងចំណោមអង្ករក្រអូបនោះ អង្ករផ្កាម្លិះ (Jasmine rice) និងផ្ការំដួលមានបរិមាណ១៨៣.៧១២តោន (លំដាប់ទី១) អង្ករក្រអូបចម្រុះ (នាងក្រអូប នាងសយ និងពូជដទៃ) មាន៦៦.២៤៤តោន (លំដាប់ទី២) អង្ករក្រអូបនាងម្លិះមាន១៩.២៨៧តោន (លំដាប់ទី៣) អង្ករក្រអូបសរីរាង្គមាន ៣.០៤៦តោន (លំដាប់ទី៤) និងសូមាលី១.៩៧៤តោន (លំដាប់ទី៥) (សូមបង្ហាញជូនក្នុងតារាងទី២នៃឧបសម្ព័ន្ធ)

- អង្ករកម្ពុជាបាននាំចេញទៅកាន់ទិសដៅចំនួន៦០ប្រទេស ក្នុងនោះប្រទេសចិនឈរលំដាប់ទី១ (១១៦.៦៣៩តោន) ប្រទេសបារាំងឈរលំដាប់ទី២ (៧៥.២៥៧តោន) ប្រទេសប៉ូឡូញឈរលំដាប់ទី៣ (៥៨.៤១០តោន) ប្រទេសនីឌ័រឡេនឈរលំដាប់ទី៣ដែរ (៥៨.៤១០តោន) ប្រទេសម៉ាឡេស៊ីឈរលំដាប់ទី៥ (៥៤.៩១៤តោន) ប្រទេសអ៊ីតាលីឈរលំដាប់ទី៦ (២៤.០៤៩តោន) សាធារណរដ្ឋឆែកឈរលំដាប់ទី៧ (២២.៥៩៧តោន) ប្រទេសប៊ែលហ្ស៊ិកឈរលំដាប់ទី៨ (១៩.៩២១តោន) ប្រទេសអង់គ្លេសឈរលំដាប់ទី៩ (១៨.៥៥៧តោន) និងប្រទេសអាល្លឺម៉ង់ឈរលំដាប់ទី១០ (១៣.០៧៦តោន)។ បរិមាណអង្ករដែលនាំចេញទៅកាន់ប្រទេសជាទិសដៅសហភាពអឺរ៉ុប២៦ប្រទេស មានបរិមាណសរុប៣៣៩.៩៧៨តោន (៦៣,១%) ទិសដៅអាស៊ាន៤ប្រទេសមានបរិមាណសរុប៦៣.៦០១តោន (១១.៨%) និងទិសដៅដទៃទៀត៣០ប្រទេសមានបរិមាណសរុប១៣៤.៨១៧តោន (២៥,១%) (សូមបង្ហាញជូនក្នុងតារាងទី៣នៃឧបសម្ព័ន្ធ)

- ការនាំចេញអង្ករមាន៨០ក្រុមហ៊ុន ដែលបរិមាណអង្ករនាំចេញត្រូវបាននាំមុខគេដោយ៖ (ទី១).ក្រុមហ៊ុន Amru Rice មានចំនួន៦០.៨៦១តោន (ទី២).ក្រុមហ៊ុន Khmer Food មានចំនួន៥៨.២៦០តោន (ទី៣).ក្រុមហ៊ុន Golden

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខៈ (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខៈ (៨៥៥) ២៣-២១៧ ៣២០
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
Phone: (023) 726 128 / 726 129, Fax: (855) 23 - 217 320